**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥៨.០១៧.១៨០ ស.ជ.ណ

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្ដីជូនដំណឹង
# ស្ដីពី
# ការជ្រើសរើសបុគ្គលិក

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងធ្វើការជ្រើសរើសបុគ្គលិកទាំងពីរភេទចំនួន ១០រូប ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ "**ខ**" កម្រិតសញ្ញាបត្រ **បរិញ្ញាបត្រ ព័ត៌មានវិទ្យា** ចូលបម្រើការងារនៅធនាគារជាតិនៃកម្ពុជា តាមរយៈការប្រឡងប្រជែង។ បេក្ខជនត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

១- មានសញ្ជាតិខ្មែរ
២- អាយុយ៉ាងច្រើនបំផុតត្រឹម ៣០ឆ្នាំ (គិតត្រឹមថ្ងៃឈប់ទទួលពាក្យ)
៣- មានចំណេះដឹងភាសាអង់គ្លេសច្បាស់លាស់
៤- បេក្ខជនត្រូវមានចំណេះដឹងពាក់ព័ន្ធនឹង ៖

**ក. ផ្នែកអភិវឌ្ឍន៍កម្មវិធី (Software Programming Developer)** ចំនួន ០៥រូប

- មានជំនាញសរសេរកម្មវិធី Object Oriented Programming Language
- មានចំណេះដឹងអភិវឌ្ឍន៍ Mobile Application ដូចជា៖ Apple iOS & Android Application
- មានជំនាញផ្នែក Report Development, Big Data Analytics, Data Mining and Cleansing Tools
- មានចំណេះដឹងផ្នែក Distributed Ledger Technologies (DLT)
- មានចំណេះដឹងផ្នែក Cryptography Technologies

**ខ. ផ្នែកគ្រប់គ្រងមូលដ្ឋានទិន្នន័យ (Database Administrator)** ចំនួន ០២រូប

- មានជំនាញគ្រប់គ្រង Oracle Database និង Database ផ្សេងទៀត
- មានបទពិសោធន៍ពាក់ព័ន្ធ Data Warehousing Management
- មានជំនាញបន្ថែមក្នុងការ Design Relational Database, Technical Design documents និង System Test scripts for Extensions, Data Conversion /Migrations, Inbound /Outbound interfaces, Reports, Forms និង Customizations
- មានលទ្ធភាពស្រាវជ្រាវ Database Programming (PL/SQL, Oracle Jdeveloper) និង Data Security

**គ. ផ្នែកសុវត្ថិភាពព័ត៌មានវិទ្យា (Information Security Officer) ចំនួន ០៣រូប**

- មានចំណេះដឹងផ្នែក Information System Security
- មានបទពិសោធន៍ត្រួតពិនិត្យ LOGs files, ការពារការជ្រៀតចូលពីខាងក្នុង និងក្រៅប្រព័ន្ធ, រៀបចំយុទ្ធសាស្ត្រឆ្លើយតបទាន់ពេលវេលាចំពោះឧប្បត្តិហេតុ ឬ Cyber-attack, ពិនិត្យមើលរចនាសម្ព័ន្ធសុវត្ថិភាពព័ត៌មាន និងធ្វើបច្ចុប្បន្នកម្មលើវិធាននិងនិតិវិធីសង្គ្រោះទិន្នន័យនាគ្រាអាសន្ន
- មានជំនាញក្នុងការធ្វើសវនកម្មលើទ្រព្យធនព័ត៌មាននិងសិទ្ធិអ្នកប្រើប្រាស់
- មានលទ្ធភាពស្រាវជ្រាវនិងរៀបចំគោលនយោបាយសុវត្ថិភាពព័ត៌មាន។

បេក្ខជនអាចមកទំនាក់ទំនងសាកសួរព័ត៌មានលម្អិតបន្ថែមទៀត នៅនាយកដ្ឋានបុគ្គលិកនៃធនាគារជាតិនៃកម្ពុជា ដែលមានទីតាំងនៅឡូត៍ ២២-២៤ តាមបណ្តោយមហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ចន្លោះពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ១៥:០០ រសៀល រៀងរាល់ថ្ងៃធ្វើការ ។

- កាលបរិច្ឆេទទទួលពាក្យប្រឡង ៖ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ
- កាលបរិច្ឆេទឈប់ទទួលពាក្យប្រឡង ៖ ថ្ងៃសុក្រ ទី៣១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ១១ : ០០នាទី
- កាលបរិច្ឆេទ មុខវិជ្ជា និង ទីកន្លែងប្រឡង ៖ ជូនដំណឹងពេលក្រោយ ។

**ត.ប.ទេសាភិបាល**
**អគ្គលេខាធិការ**

**អ៊ូ ចាន់តារា**